**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ០០១ សហវ

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០៤

# សារាចរណែនាំ

## ស្តីពី

## ការកែលំអនីតិវិធីអនុវត្តថវិកា

- យោងអនុក្រឹត្យលេខ ៨១ អនក្រ.កប ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង-ស្ថាប័ន ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការ សាធារណៈរដ្ឋបាល

- យោងអនុក្រឹត្យលេខ ៨២ អនក្រ.កប ចុះថ្ងៃទី១៦ ខែ វិច្ឆិកាឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

- យោងប្រកាសលេខ ៦១៩ សហវ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ

- អនុលោមតាមស្មារតីនៃអង្គប្រជុំ របស់គណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ នាថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៣

ដើម្បីធានាការអនុវត្តន៍ថវិការដ្ឋប្រកបដោយប្រសិទ្ធភាពផ្សារភ្ជាប់ជាមួយការគ្រប់គ្រងសាច់ប្រាក់ស្របតាមគោលការណ៍អភិបាលកិច្ចល្អក្នុងក្របខ័ណ្ឌកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីវិធានការមួយចំនួនក្នុងការអនុវត្តន៍នីតិវិធីអនុវត្តថវិកា ដូចតទៅ:

### ១. អំពីការគ្រប់គ្រងឥណទានថវិកា

#### ក -វិធានការពង្រឹងវិន័យថវិកា

កិច្ចការនេះវាជាភារៈទទួលខុសត្រូវផ្ទាល់របស់ក្រសួង-ស្ថាប័ននានា និងមន្ទីរជំនាញគ្រប់ខេត្ត-ក្រុង តែក៏ស្ថិតនៅក្រោមអំណាចនៃការត្រួតពិនិត្យនិងគ្រប់គ្រងផ្ទាល់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផងដែរ ។ ដូចនេះ ដើម្បីបង្កើនភាពទទួលខុសត្រូវក្នុងកិច្ចប្រតិបត្តិការចំណូល-ចំណាយក៏ដូចជាក្នុងសកម្មភាពគ្រប់គ្រងថវិកាជាតិ គ្រប់ក្រសួង-ស្ថាប័ននានារួមទាំងមន្ទីរជំនាញគ្រប់ខេត្ត-ក្រុង និង អង្គភាពជំនាញ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ថិតក្នុងស្ថានភាពលំបាកចំពោះមុខត្រូវមានវិធានការពង្រឹងវិន័យថវិកាឱ្យកាន់តែប្រសើរតាមបរិបថចំណាយហិរញ្ញវត្ថុសាធារណៈនិងតាមភារកិច្ចរៀង១ខ្លួន ដូចតទៅ :

**អំពីចំណូល :**

+ ត្រូវបង់ចូលថវិការដ្ឋទាំងអស់ មិនត្រូវផាត់ទាត់ជាមួយចំណាយឡើយ ។

+ ត្រូវធ្វើចលនាប្រមូលផ្តុំប្រាក់ចំណូលគ្រប់ប្រភេទពីគ្រប់ប្រភព ហើយកត់ត្រាចុះបញ្ជី និងបង់ចូលថវិការដ្ឋ ឱ្យបានទៀងទាត់តាមច្បាប់និងបទបញ្ជាជាធរមាន ។

+ ត្រូវតាមដានជាប្រចាំនូវសក្ខីប័ត្របង់ចំណូលជាមួយបញ្ជីសំរង់ចំណូល ហើយផ្ទៀងផ្ទាត់រៀងរាល់ខែ ជាមួយសៀវភៅគល់បញ្ជីបង្កាន់ដៃ ។

+ ត្រូវតឹងទារបំណុលពីអ្នកជំពាក់បំណុលរដ្ឋ សំដៅបញ្ចៀសឱ្យបាននូវការខាតបង់ចំណូលថវិកាជាតិ ។

+ ត្រូវលុបបំបាត់ឱ្យអស់ និងជាបន្ទាន់នូវទង្វើរក្សាប្រាក់ចំណូលសំរាប់ចំណាយ ។ សាច់ប្រាក់អាចដកល់ទុកបានក្នុងបេឡាមិនត្រូវឱ្យលើសពីចំនួនបានកំណត់ក្នុងប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ ០១៤ ប្រក. សហវ.រជ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៧ នោះឡើយ ។ ចំនួនសាច់ប្រាក់ដែលភ្នាក់ងារ ឬ អង្គភាពនិមួយៗអាចរក្សាទុកក្នុងបេឡារបស់ខ្លួនត្រូវបានកំណត់ត្រឹមចំនួន :

- ចំពោះរដ្ឋទេយ្យករចំណូលមិនលើសពីចំនួន ២.០០០.០០០រៀល ( ពីរលានរៀល)
- ចំពោះគណនេយ្យកររដ្ឋបាលហិរញ្ញវត្ថុ( នាយកដ្ឋានពន្ធដារនិងទីចាត់ការគយនិងរដ្ឋាករ) :
  - នៅរាជធានីភ្នំពេញមិនឱ្យលើសពី ៥.០០០.០០០រៀល ( ប្រាំលានរៀល)
  - នៅតាមបណ្តាខេត្ត-ក្រុងមិនឱ្យលើសពី ២.០០០.០០០រៀល ( ពីរលានរៀល)

**អំពីចំណាយ :**

+ ត្រូវចំណាយក្នុងក្របខ័ណ្ឌឥណទានថវិកាដែល ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំអនុញ្ញាត ។

+ ត្រូវប្រតិបត្តិឱ្យបានហ្មឹងម៉ាត់និងត្រឹមត្រូវតាមនីតិវិធី និងតាមបរិបទនៃការត្រួតពិនិត្យហិរញ្ញវត្ថុ ដូចមានខ្លឹមសារចែងក្នុងអនុក្រឹត្យ លេខ ៨១ អនក្រ.កប ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ។

+ ត្រូវធ្វើឱ្យបានត្រឹមត្រូវនិងមានតម្លាភាព នៅក្នុងការអនុវត្តន៍បទបញ្ជានិងនីតិវិធីលទ្ធកម្មសាធារណៈ ។

+ ត្រូវខិតខំសន្សំសំចៃនិងត្បិតត្បៀតលើចំណាយថវិការដ្ឋ ។

+ ត្រូវលុបបំបាត់ជាបន្ទាន់នូវទង្វើខុសច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដូចជា :

- ទម្លាប់យកចំណូលទៅចំណាយមុន រួចចាំស្នើសុំថវិកាមកបំពេញវិញ
- ទម្លាប់ខ្ចីសំភារៈបរិក្ខារពីអតិថិជនប្រើប្រាស់មុន ដោយគ្មានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មិនយកចិត្តទុកដាក់ក្នុងការប្រមូលឯកសារទូទាត់ចំណាយរដ្ឋទេយ្យបុរេប្រទានពិសេសទូទាត់ថវិកា បុរេប្រទានមិនទាន់តាមកាលកំណត់
- ចំណាយក្រៅរង្វង់ថវិកាអនុម័ត តាមនីតិវិធីចំណូលព្រម-ចំណាយព្រម ។

+ ត្រូវបង្កើនកិតទទួលខុសត្រូវក្នុងការគ្រប់គ្រងចំណាយសាធារណៈ សំដៅរំលេចឱ្យឃើញនូវ :

- លទ្ធផលល្អប្រសើរនិងមានប្រសិទ្ធភាពខ្ពស់
- តម្លាភាពនិងគណនេយ្យភាព ។

+ ត្រូវតាមដានការអនុវត្តន៍ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងប្រចាំឆ្នាំ សំខាន់គឺត្រូវអនុវត្តឱ្យបានល្អ តាមកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសដោយបែងចែកលំអិតតាមខែ និងដោយ**ផ្អែកលើសមិទ្ធិផលជាក់ស្តែងនៃការប្រមូលចំណូល** ។

+ ត្រូវខិតខំរឹតបន្តឹងវិធីគ្រប់គ្រងចំណាយថវិកា ដោយមិនអនុញ្ញាតឱ្យមានការអនុវត្តន៍ចំណាយណាមួយ រំលោភលើគោលការណ៍នៃបរិបថចំណាយឡើយ ។

+ ត្រូវប្រមូលផ្តុំពតិមាននិងការបូកសរុបលើការសន្យាចំណាយ និងការចេញអាណត្តិបើករាល់ខែ ដោយធានាមិនឱ្យមានអាណត្តិកកស្ទះនៅធនាគារជាតិ លើសពីមួយភាគដប់ពីរនៃចំណូលចរន្តប្រចាំឆ្នាំឡើយ ។

+ ត្រូវផ្ទៀងផ្ទាត់តួលេខអនុវត្តចំណូល-ចំណាយថវិការវាងគណនេយ្យរដ្ឋបាលរបស់ក្រសួងចំណាយ ជាមួយនឹងគណនេយ្យករចំណូល-ចំណាយរបស់ធនាគារជាតិ ។

## ខ-អំពីទិដ្ឋាការនៃការសន្យាចំណាយ

- ដើម្បីឱ្យការអនុវត្តន៍នីតិវិធីលទ្ធកម្មសាធារណៈប្រព្រឹត្តទៅមានភាពងាយស្រួល ការផ្តល់ធានាចំណាយថវិកា សំរាប់ឆមាសទី១យ៉ាងខ្ពស់បំផុតត្រឹម ៦០% ។
- នៅដើមខែមិថុនានៃឆ្នាំថវិកានីមួយៗ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិនិត្យសារឡើងវិញនូវសភាពការណ៍ អនុវត្តចំណូល-ចំណាយថវិកា ដោយធ្វើការវាយតម្លៃនូវសភាពការណ៍អនុវត្តថវិកាឆមាសទី១ និងធ្វើការប៉ាន់ស្មានអនុវត្ត ឆមាសទី២ ។ ក្នុងករណីសភាពការណ៍អនុវត្តថវិកាមានការប្រែប្រួលច្រើនខុសពីការគ្រោងទុក ត្រូវធ្វើការសម្របសម្រួល ការអនុវត្តន៍ថវិកាឆមាសទី២ ដោយមានវិធានការបង្កើនចំណូលនិងកាត់បន្ថយចំណាយថវិកា ឬ ត្រូវរៀបចំសេចក្តីព្រាង ច្បាប់ហិរញ្ញវត្ថុកែតំរូវ ។
- ការធានាចំណាយសំរាប់ឆមាសទី២ ត្រូវធ្វើឡើង តាមការប៉ាន់ស្មានអនុវត្ត ៦ខែចុងឆ្នាំ ឬតាមការប្រែប្រួល ឥណទានថវិកាកែតំរូវ ។

## គ-អំពីទិដ្ឋាការលើអាណត្តិបើកប្រាក់

ដំណាក់កាលនៃការចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ គឺធ្វើក្រោយពេលដែលទំនិញទាំងឡាយត្រូវបានប្រគល់-ទទួល ឬការងារ ក៏ដូចជាសេវាទាំងឡាយត្រូវបានសម្រេចរួចហើយ ។ អាណាប័កត្រូវធ្វើការចាត់ចែងទូទាត់ជំរះចំណាយតាមចំនួន ទឹកប្រាក់ពិតប្រាកដ ក្រោយពីបានធ្វើការផ្ទៀងផ្ទាត់ជាក់លាក់និងត្រឹមត្រូវ ប៉ុន្តែ ទោះយ៉ាងនេះក្តី រាល់ការរៀបចំ អាណត្តិកិច្ច អាណាប័កត្រូវគោរពតាមបទប្បញ្ញត្តិទាំងឡាយនៃសំណុំលិខិតយុត្តិការនិងកិច្ចសន្យា និងកម្មវិធីចំណូល-ចំណាយសាច់ប្រាក់ ប្រចាំខែ ដូចតទៅ :

- ត្រូវភ្ជាប់មកជាមួយនូវលិខិតយុត្តិការពាក់ព័ន្ធទាំងឡាយ សំរាប់ជាសំអាងក្នុងការទូទាត់ និងផ្តល់ចំណាយ
- ត្រូវផ្ទៀងផ្ទាត់និងពិនិត្យឱ្យបានល្អិតល្អន់អំពីសុពលភាពនៃសំណុំលិខិត ។
- ត្រូវបញ្ជៀសនូវ :
  - ការចុះកិច្ចសន្យាផ្គត់ផ្គង់ដែលតម្រូវឱ្យធ្វើការទូទាត់ទាំងស្រុងតែម្តង ដែលមិនសមស្របទៅនឹង

កម្មវិធីសាច់ប្រាក់ និងលទ្ធភាពថវិកា ។

- ការបោះផ្សាយអាណត្តិបើកប្រាក់ដោយគំហុក លើសពីកម្មវិធីសាច់ប្រាក់ដែលបានគ្រោងទុក ។
- ការបង្អូកឯកសារត្រូវទូទាត់ឱ្យនៅពួនគរហូតដល់ចុងឆ្នាំទើបរៀបចំធ្វើអាណត្តិកិច្ច ជាហេតុធ្វើឱ្យប៉ះពាល់ដល់កម្មវិធីសាច់ប្រាក់ចុងឆ្នាំ ។

- ត្រូវធ្វើត្រឡប់វិញឬព្យួរទុកការទូទាត់នូវអាណត្តិបើកប្រាក់ទាំងឡាយ ដែលមានមូលហេតុដូចខាងក្រោម:
  - ភាពមិនទំនេរនៃឥណទាន
  - ពុំមានទិដ្ឋាការសន្យាចំណាយ
  - ពុំមានលិខិតយុត្តិការបញ្ជាក់ពីសេវាបានធ្វើហើយ ឬមិនត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុសាធារណៈ
- រាល់ការជំទាស់ ត្រូវមានការសម្រេចនិងជូនដំណឹងតាមនីតិវិធីរដ្ឋបាល ។

## ឃ-អំពីចលនាឥណទានថវិកា

ការធ្វើចលនាឥណទានពីជំពូកមួយទៅជំពូកមួយ ទោះបីត្រូវបានអនុញ្ញាតក៏ដោយ ក៏ការបង្វែរឥណទានច្រើន ហួសហេតុ នឹងបញ្ជាក់អោយឃើញថាការរៀបចំគំរោងថវិកាមិនបានស្របទៅតាមតម្រូវការចំណាយជាក់ស្តែងរបស់ខ្លួន ។ ដូច្នេះ ក្នុងការអនុវត្តន៍ថវិកាពីដើមត្រីមាសទី១ រហូតដល់ចុងត្រីមាសទី៣ នៃឆ្នាំថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិន អនុញ្ញាតឱ្យក្រសួង-ស្ថាប័ននិងមន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត-ក្រុង ធ្វើចលនាឥណទានថវិកាដោយបង្វែរពីជំពូកមួយទៅជំពូកមួយ នៅក្នុងក្របខ័ណ្ឌប្រភេទអន្តរាគមន៍តែមួយដូចគ្នាបានទេ ក្នុងនោះ ហាមធ្វើចលនាឥណទាន ដោយធ្វើការ បង្វែរ ឥណទានពីជំពូកមួយដែលមានចរិតលក្ខណៈជាឥណទាន " វាយតំលៃបាន" ទៅជំពូកមួយទៀតដែលមានចរិតលក្ខណៈ ជាឥណទាន "កំហិត" ដូចជា : ការបង្វែរឥណទានពី ជំពូក១០ (បៀវត្ស និង ប្រាក់បំណាច់) ទៅជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច) ទោះបី ជំពូកទាំងពីរនេះស្ថិតនៅក្នុងក្របខ័ណ្ឌប្រភេទ មធ្យោបាយ សេវា តែមួយដូចគ្នាក៏ដោយ តែជំពូកទាំងពីរនេះជាឥណទាន មានចរិតលក្ខណៈផ្ទុយគ្នា ។ នៅក្នុងការអនុវត្តន៍ ថវិកា បើមានការខ្វះខាតឥណទានជំពូក ១០ ឬជំពូក ៣១ ដែលមានចរិតលក្ខណៈជាឥណទាន " វាយតំលៃបាន" ក្រសួង-ស្ថាប័ននិងមន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត-ក្រុង ត្រូវលើកសំណើសុំនិយ័តភាពពីជំពូកដទៃទៀត មកបំពេញបន្ថែម តាមការចាំបាច់ ។

## ២_អំពីការគ្រប់គ្រងប្រាក់បុរេប្រទាន

កន្លងមក នៅក្នុងបរិបទចំណាយហិរញ្ញវត្ថុសាធារណៈ មានការអនុវត្តន៍បន្ថែមនូវយន្តការបើកផ្តល់ចំណាយតាមរូបភាព រជ្ជទេយ្យបុរេប្រទានផង និងបុរេប្រទានផង ដោយផ្អែកតាមសំណូមពរជាយថាហេតុរបស់បណ្តាក្រសួងនិងស្ថាប័ន ។ ប្រការនេះ បានធ្វើឱ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកាជាតិ សំខាន់គឺប៉ះពាល់ដល់កម្មវិធីចំណូល-ចំណាយសាច់ប្រាក់ប្រចាំខែ ដែលជាហេតុបណ្តាលឱ្យកើតមានបញ្ហាឯកសាច់ប្រាក់បុរេប្រទាន ទៅប្រើប្រាស់មិនបាននៅក្នុងពេលបច្ចុប្បន្ននេះ។ ដូចនេះ គ្រប់ក្រសួង-ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង ត្រូវតែកាត់បន្ថយនិងបញ្ចៀសឱ្យបាននូវ ទម្លាប់ពង្រីកយន្តការប្រើប្រាស់ថវិកាបុរេប្រទាននេះ ។

ដើម្បីបន្ថយបាននូវបាតុភាពមិនប្រក្រតីនេះ គ្រប់ក្រសួង-ស្ថាប័ន និងគ្រប់ខេត្ត-ក្រុងត្រូវកែលំអនីតិវិធីចំណាយតាមរូបភាពបុរេប្រទាននេះ ដូចតទៅ :

១- ត្រូវអនុវត្តនីតិវិធីចំណាយដូចធម្មតាដើម្បីបញ្ចៀសចំណាយតាមបែបបុរេប្រទាន ។

២- ត្រូវលើកសំណើសុំចំណាយថវិកាបុរេប្រទានចំពោះតែចំណាយទាំងឡាយណាដែលកើតឡើងក្នុងករណីចាំបាច់ និងបន្ទាន់បំផុតប៉ុណ្ណោះ ។

៣- ត្រូវលើកកម្មវិធីស្នើសុំចំណាយថវិកាបុរេប្រទានតាមកាលបរិច្ឆេទជាក់លាក់ ដើម្បីឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រៀមដាក់បញ្ចូលក្នុងកម្មវិធីសកម្មភាពសាច់ប្រាក់ជាមុន ។

៤- ត្រូវប្រមែប្រមូលសក្ខីប័ត្រ និងយកចិត្តទុកដាក់ធ្វើអាណត្តិនិយ័តកម្ម ដើម្បីទូទាត់ថវិកាបុរេប្រទានឱ្យបានតាមកាលបរិច្ឆេទកំណត់ដូចតទៅ :

ក-ចំពោះប្រាក់បុរេប្រទានមានលក្ខណៈចាំបាច់ និង បន្ទាន់

- នៅចុងត្រីមាសទីមួយនៃឆ្នាំថវិកា ត្រូវជំរះបញ្ជីឱ្យបានរួចរាល់ជាអាណត្តិបោះផ្សាយ និងត្រូវបានរតនាគារជាតិ និងអង្គភាពគ្រប់គ្រងរូបិយប័ណ្ណលុបចេញពីបញ្ជីបុរេប្រទានយ៉ាងតិចចំនួន **២ ភាគ ៣** នៃប្រាក់បុរេប្រទានទាំងអស់ដែលដល់ថ្ងៃកំណត់ឱ្យជំរះបញ្ជីទូទាត់ក្នុងអំឡុងត្រីមាសទី១ ។ ក្នុងករណីក្រសួង-ស្ថាប័នណាដែលមិនជំរះបញ្ជីជាស្ថាពរនូវចំនួន ២ភាគ៣ ក្នុងដំណាក់កាលត្រីមាសទី១នេះទេ ក្រសួង-ស្ថាប័ននោះមិនត្រូវបានអនុញ្ញាតឱ្យបន្តធ្វើសំណើប្រាក់បុរេប្រទាន ជាយថាហេតុនៅដំណាក់កាលត្រីមាសទី២ទៀតទេ ។
- ត្រីមាសទី២ ត្រូវជំរះបញ្ជី ១ ភាគ ៣ ដែលនៅសល់ពីត្រីមាសទី១ និង ២ភាគ៣ នៃត្រីមាសទី២ ។
- ត្រីមាសទី ៣ ក៏ត្រូវធ្វើកិច្ចជំរះបញ្ជីតាមបែបបទនិងនីតិវិធីដូចបានកំណត់នៅត្រីមាសទី២ ដែរ ។ ក្នុងករណីក្រសួង-ស្ថាប័នណា ដែលមិនធ្វើកិច្ចជំរះបញ្ជីជាស្ថាពរនូវចំនួន ១ ភាគ៣ ដែលនៅសល់ពីត្រីមាសមុន និង ២ ភាគ ៣ នៃត្រីមាសបន្ទាប់ ក្រសួង-ស្ថាប័ន នោះមិនត្រូវបានអនុញ្ញាតឱ្យបន្តធ្វើសំណើប្រាក់បុរេប្រទានជាយថាហេតុនៅដំណាក់កាលត្រីមាសបន្ទាប់ ទៀតទេ ។

- ចំពោះត្រីមាសទី៤ ត្រូវជំរះបញ្ជីជាស្ថាពរនូវចំនួន ១ភាគ៣ ដែលនៅសល់ ពីត្រីមាសទី៣ ហើយសំណើប្រាក់បុរេប្រទានជាយថាហេតុសំរាប់ត្រីមាសទី៤នេះ **អាចធ្វើទៅបានលុះត្រាតែមានឥណទាននៅសល់ទំនេរ** ក្នុងថវិកាបាន់ស្មានចុងឆ្នាំ ឬថវិកាកែតំរូវ ។
- ជាទូទៅ មិនត្រូវមានប្រាក់បុរេប្រទានដែលមិនបានជំរះបញ្ជីចប់សព្វគ្រប់ នាដំណាច់ឆ្នាំនីមួយៗឡើយ ។ ដូចនេះប្រាក់បុរេប្រទាន ត្រូវតែបានគ្រប់គ្រងយ៉ាងហ្មត់ចត់ និងត្រូវបានជំរះបញ្ជីជាស្ថាពរ ជាបណ្តើរៗ ក្នុងខែនិមួយៗ និងបានទាំងស្រុងក្នុងអំឡុងពេលអនុវត្តឆ្នាំថវិកានោះតែម្តង ។ ធ្វើរបៀបនេះ ទើបបញ្ចៀសបានការពូនគរប្រាក់បុរេប្រទាន ដែលកន្លងមកតែងធ្វើការជំរះបញ្ជីនាចុងឆ្នាំតែប៉ុណ្ណោះ ឬមិនព្រមជំរះបញ្ជី ដោយទុកចោលពីមួយឆ្នាំ ទៅ មួយឆ្នាំ ។
- ប្រសិនបើមានប្រាក់បុរេប្រទានរបស់ក្រសួង-ស្ថាប័នណាមួយនៅសល់មិនបានជំរះបញ្ជី ហើយស្ថិតនៅក្នុងបញ្ជីគណនេយ្យរបស់រតនាគារជាតិ ឬ អង្គភាពគ្រប់គ្រងរូបិយប័ណ្ណ ក្នុងកិច្ចអនុវត្តន៍ថវិកាឆ្នាំ ២០០៣ និងឆ្នាំខាងមុខជាបន្តបន្ទាប់

ក្រសួង-ស្ថាប័ននោះ នឹងមិនត្រូវបានជំរុញលើកទឹកចិត្តអោយបន្តអនុវត្តយន្តការប្រាក់បុរេប្រទាន នៅឆ្នាំបន្ទាប់ឡើយ ។

**ខ-ចំពោះប្រាក់បុរេប្រទានមានលក្ខណៈជាប្រាក់រំដោះ ឬ ក្នុងល័ក្ខខ័ណ្ឌចែងដោយចេទបញ្ញាជាធរមាន**

ផ្អែកតាមកិច្ចសន្យាជាធរមាន ប្រាក់បុរេប្រទានប្រភេទនេះអាចប្រគល់អោយអ្នកផ្គត់ផ្គង់បាន តែមិនអោយលើស ពីចំនួន ២៥% នៃតំលៃកិច្ចសន្យាឡើយ ។ ប្រាក់បុរេប្រទាននេះនឹងត្រូវបានជំរះបញ្ជីជាបណ្តើរៗ តាមកិច្ចសន្យាដែលបានចែង ។

## ៣. អំពីការគ្រប់គ្រងកម្មវិធីចំណូល-ចំណាយ

យោងតាមសារាចរលេខ ០០១ សហវ.ថហ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០២ ស្តីពីការណែនាំអនុវត្តថវិកាឆ្នាំ ២០០២ ការរៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស នៅតែជាធរមាន ។ ក៏ប៉ុន្តែ ការរៀបចំកម្មវិធីចំណូល-ចំណាយនេះ ត្រូវធ្វើការកែលំអ ដូចខាងក្រោម:

- ត្រូវគិតបញ្ចូលតំរូវការប្រាក់បុរេប្រទាន រដ្ឋទេយ្យបុរេប្រទាន អាណត្តិបើកប្រាក់ដកល់ទុកនៅរតនាគារជាតិ និង អាណត្តិបើកប្រាក់កកស្ទះរបស់ក្រសួង-ស្ថាប័ននានាទៅក្នុងកម្មវិធីចំណូល-ចំណាយថវិកា ប្រចាំខែ ត្រីមាស ចាប់ពីដើម ដំបូងនៃការអនុវត្តន៍ថវិកាឆ្នាំ ២០០៤ តទៅ ។

- ត្រូវលុបបំបាត់ការធ្វើកម្មវិធីបន្ថែមចំណាយ ដើម្បីបោះផ្សាយអាណត្តិបន្ថែមជាស្វ័យប្រវត្តិ នៅក្នុងកម្មវិធី ចំណូល-ចំណាយប្រចាំត្រីមាស ។ អាចបន្ថែមកម្មវិធីចំណាយជូនបានតែក្នុងករណីមានសល់កម្មវិធីក្រោយពីធ្វើការផ្ទៀងផ្ទាត់ រវាងកម្មវិធីនិងការអនុវត្តន៏ជាក់ស្តែង ។

- ត្រូវធ្វើការកែតំរូវ មួយខែម្តងនូវតួលេខព្យាករណ៍ចំណូលប្រចាំខែ ជាមួយនឹងតួលេខចំណូលដែលបាន ប្រមូល ជាក់ស្តែងដោយផ្អែកតាមតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ (TOFE) ក្នុងខែកន្លងមករួចហើយពិនិត្យវាយតំលៃចំណាយ ក្នុងស្រុកដែលរួមមានចំណាយចរន្ត ចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស និងចំណាយរំលស់ បំណុលជាក់ស្តែង ប្រៀបធៀបជាមួយចំណូលក្នុងស្រុកជាក់ស្តែងក្នុងខែនោះ ។ ក៏ប៉ុន្តែ ការប្រៀបធៀបរវាង ចំណូល-ចំណាយតែប៉ុណ្ណេះមិនទាន់ សន្និដ្ឋានបានថាសាច់ប្រាក់ទំនេរនៅរតនាគារជាតិបានទេ ពីព្រោះការគ្រប់គ្រង សាច់ប្រាក់បច្ចុប្បន្ន ត្រូវយកចំណូលជា សាច់ ប្រាក់ក្នុងខែ សំរាប់បើកផ្តល់បុរេប្រទានផង សំរាប់បើកផ្តល់ (ទូទាត់) បំណុលសាច់ប្រាក់ដែលពុទ្ធគរ នាឆ្នាំមុនៗផង ឬអាណត្តិ បើកប្រាក់ PAPឆ្នាំកន្លងមកផង ។ល។ ម្យ៉ាងវិញទៀត ក៏មានចំណូលខ្លះកត់ត្រាកើនឡើងក្នុងខែ តែយកទៅកាត់កងជាមួយ បំណុលក្រុមហ៊ុនឆ្នាំមុន ។ ដូចនេះ ផ្នែកចំណាយមិនត្រូវបានកត់ត្រាម្តងទៀតក្នុងខែនោះបានឡើយ ។ ក្នុងករណីនេះនឹងនាំឱ្យ ឃើញថា ចំណូលក្នុងខែកើន ខ្ពស់ តែចំណាយក្នុងខែវិញនៅទាប ។

- បញ្ជៀសការធ្វើកម្មវិធីចំណាយប្រចាំខែ ត្រីមាស ឱ្យស្មើនឹង ចំនួនព្យាករណ៍ចំណូលនៃខែ ត្រីមាសនោះគឺត្រូវ ធ្វើឱ្យទាបជាង ៧ ទៅ ១០%នៃការព្យាករណ៍ចំណូលខែ ត្រីមាស ។

- រាល់កម្មវិធីចំណូល-ចំណាយ ត្រូវបានដាក់ជូន គណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ ពិនិត្យនិងអនុម័ត មុននឹងដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំរេច ។

## ៤. អំពីការគ្រប់គ្រងបំណុលសាច់ប្រាក់ក្នុងអាណត្តិមិនបានទូទាត់

ដើម្បីបន្ថយស្តុកនៃបំណុលសាច់ប្រាក់ជាទូទៅ និង ដោយអនុវត្តនូវសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៤ តទៅ ធនាគារជាតិនិងអង្គភាពគ្រប់គ្រងរូបិយប័ណ្ណត្រូវរៀបចំសន្សំ សាច់ប្រាក់ពីចំណូលថវិការដ្ឋតាមឥណទានដែលបានគ្រោងក្នុងជំពូក៩៣ ដែលបានកំណត់ក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៤ សំដៅកាត់បន្ថយស្តុកនៃបំណុលសាច់ប្រាក់ឱ្យបានជាបណ្តើរៗពីក្នុងអាណត្តិមិនទាន់ទូទាត់ រហូត បំណុលប្រភេទនេះបញ្ចប់ជាស្ថាពរ ។ ទន្ទឹមនេះដែរ មិនអនុញ្ញាតឱ្យធ្វើនិយ័តភាពពីជំពូក៩៣នេះ ទៅជំពូកផ្សេងទៀតទេ ។

## ៥. <u>អំពីការគ្រប់គ្រងបំណុលសារពើពន្ធនិងបំណុលពុំមែនសារពើពន្ធ</u>

ចំណូលថវិកាត្រូវតែខិតខំគៀងគរប្រមូលផ្តុំនិងដាក់បញ្ចូលក្នុងធនាគារជាតិទាំងអស់ ។ និយាយដោយឡែក ចំណូលពីបំណុលពន្ធដារ បំណុលពន្ធគយនិងរដ្ឋាករ និងបំណុលពុំមែនសារពើពន្ធដែលជំពាក់រដ្ឋផ្សេងៗទៀត ដូចជាបំណុលពីការលក់និងជួល ទ្រព្យសម្បត្តិរដ្ឋ... ។ល ។ ត្រូវមានវិធានការតឹងទារដូចតទៅ :

- មិនអនុញ្ញាតឱ្យបោះបង់ ឬលុបចោលនូវ បំណុលពន្ធ ឬបំណុលជំពាក់រដ្ឋណាមួយខុសពីបទប្បញ្ញត្តិឡើយ មានជាអាទិ៍ :

  - បំណុលពន្ធដារ
  - បំណុលពន្ធគយនិងរដ្ឋាករ
  - បំណុលពុំមែនសារពើពន្ធ ដូចជា បំណុលពីការលក់ ជួល ផ្ទេរភោងចក្រ សហគ្រាស អចលនទ្រព្យផ្សេងៗរបស់ក្រសួង-ស្ថាប័ន បំណុលពីទេសចរណ៍ បំណុលពីទិដ្ឋាការនិងលិខិតឆ្លងដែន បំណុលប្រៃសណីយ៍និង ទូរគមនាគមន៍ បំណុលពីវិស័យអាកាសចរ និងពត៌មាន... ។ល ។

- នាយកដ្ឋានពន្ធដារនិងទីចាត់ការគយនិងរដ្ឋាករ ត្រូវផ្តល់បញ្ជីបំណុលពន្ធរបស់ក្រុមហ៊ុន ដែលបានធ្វើការផ្គត់ផ្គង់សំភារៈ សេវា សំណង់ ជូនរដ្ឋ ហើយដែលក្រុមហ៊ុនទាំងនោះជំពាក់បំណុលពន្ធមិនទាន់ទូទាត់ ឱ្យបានជាប្រចាំជូននាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិសេសជូនធនាគារជាតិនិងអង្គភាពគ្រប់គ្រងរូបិយប័ណ្ណ ដើម្បីកាត់កង ទូទាត់ជាស្វ័យប្រវត្តិនូវបំណុលពន្ធទាំងនោះលើអាណត្តិដែលបានបោះផ្សាយ ។ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋត្រូវគ្រប់គ្រងបំណុលពុំមែនសារពើពន្ធឱ្យបានជាប្រចាំព្រមទាំងផ្តល់របាយការណ៍បំណុលទាំងនេះជូននាយកដ្ឋានពាក់ព័ន្ធ ជាពិសេសជូនធនាគារជាតិនិងអង្គភាពគ្រប់គ្រងរូបិយប័ណ្ណដើម្បីជាមូលដ្ឋានទិន្នន័យសំរាប់វិធានការទូទាត់កាត់កងលើអាណត្តិបោះផ្សាយ ។ ធនាគារជាតិ អង្គភាពគ្រប់គ្រងរូបិយប័ណ្ណ នាយកដ្ឋានពន្ធដារ ទីចាត់ការគយនិងរដ្ឋាករ និងនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋត្រូវផ្ទៀងផ្ទាត់ជាមួយគ្នានូវចំនួនទឹកប្រាក់បំណុលទាំងនោះឱ្យបានត្រឹមត្រូវ ។

## ៦. <u>អំពីកិច្ចជំរះបញ្ជី និង ការទូទាត់</u>

- កិច្ចជំរះបញ្ជីគឺជាកម្មវត្ថុនៃការផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវពិតប្រាកដនៃចំណាយទាំងឡាយរបស់រដ្ឋ ។ ចំណាយថវិការដ្ឋត្រូវជំរះដោយអាណាប័ក ។ កិច្ចជំរះបញ្ជីនេះត្រូវធ្វើឡើងក្រោយចំណាយទាំងឡាយរបស់រដ្ឋត្រូវបាន បញ្ចប់ ព្រមជាមួយនិងការបញ្ជាក់ពីភាពត្រឹមត្រូវលើគ្រប់សក្ខីប័ត្រ ។ ដើម្បីសំរេចកិច្ចជំរះចំណាយនេះ អាណាប័ក ត្រូវបំពេញ អាណត្តិបើក

ប្រាក់ ។ អាណត្តិបើកប្រាក់ ដាច់ខាតត្រូវផ្ទងទិដ្ឋាការពីអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ។ គ្មានទិដ្ឋាការរបស់ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ អាណត្តិបើកប្រាក់នឹងគ្មានតំលៃទេចំពោះគណនេយ្យករមុខការនៃរតនាគារជាតិ ។

- **ការទូទាត់គឺជាប្រព្រឹត្តកម្មដែលអាណាប័កត្រូវតែរំដោះបំណុលថវិការដ្ឋ រួមមាន រដ្ឋទេយ្យបុរេប្រទាន** និង **ថវិកាបុរេប្រទាន** ។ រដ្ឋទេយ្យបុរេប្រទាន និងថវិកាបុរេប្រទាន **ត្រូវកត់ត្រាតាមជានការសន្យាចំណាយដូចធម្មតា** ទោះប្រាក់បុរេប្រទានជារូបិយប័ណ្ណអន្តរជាតិតាមរយៈមូលប្បទានប័ត្រក៏ដោយ ។ ធ្វើបែបនេះដើម្បីអាចមានឥណទាន ត្រៀមទុកទូទាត់ ។ រដ្ឋទេយ្យករ មិនត្រូវដំអក់ គឺត្រូវរួតរះប្រមូលលិខិតយុត្តិការចំណាយដើម្បីរៀបចំជារបាយការណ៍ បូកសរុប យ៉ាងយូរបំផុតរយៈពេល ០១ ខែ ចាប់ពីកាលបរិច្ឆេទបានដកប្រាក់ពីរតនាគារជាតិ ព្រមទាំងរៀបចំអាណត្តិនិយ័តកម្មដើម្បីដាក់ជូនអាណាប័ក ពិនិត្យនិងចុះហត្ថលេខា ។ ភាពព្រងើយកន្តើយមិនប្រញាប់ប្រញាល់ប្រមូលលិខិតយុត្តិការនិងរៀបចំធ្វើអាណត្តិនិយ័តកម្មនិងធ្វើឱ្យ មានផលប៉ះពាល់ ដោយថាហេតុ :
  - មិនបានកត់ត្រានិងឆ្លុះបញ្ចាំងចំណាយថវិការដ្ឋ ។
  - កាត់បន្ថយការចំណាយឥណទាននៃឆ្នាំបន្ទាប់ ។
- កិច្ចជំរះបញ្ជីនិងការទូទាត់ចំណាយ បើក្នុងករណីអាណាប័កក្រសួង-ស្ថាប័នណាមួយ ឬមន្ទីរជំនាញខេត្ត-ក្រុងណាមួយនៅប្រកាន់ភាពព្រងើយកន្តើយនិងរំរងួសមិនព្រមចាត់វិធានការឱ្យអង្គភាពជំនាញក្រោមឱវាទធ្វើការទូទាត់ជំរះបញ្ជីចំណាយបានទាន់ពេលវេលាកំណត់ក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកាទេនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងចាត់បញ្ជាឱ្យធ្វើអធិការកិច្ចភ្លាម ហើយអាចនឹងឈានដល់ធ្វើសេចក្តីរាយការណ៍ជូនអាជ្ញាធរសវនកម្មជាតិ ដើម្បីចុះត្រួតពិនិត្យរកឱ្យឃើញពីការមិនគោរពវិន័យក្នុងកិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកាជាតិ ក៏ដូចជាការមិនទទួលខុសត្រូវរបស់អ្នកដែលមានតួនាទីគ្រប់គ្រងប្រាក់កាសសាធារណៈដែរ ។

## ៧. <u>អំពីការគ្រប់គ្រងថវិកា និង គណនេយ្យ របស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា នៅបរទេស</u>

ដោយផ្អែកតាមស្មារតីសារាចររបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិលេខ ៥៦០៨ កបទ.សអ.ខទ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីចំណាយរបស់ស្ថានទូត និងរបាយការណ៍ប្រចាំខែ គ្រប់ស្ថានតំណាងនៃ ព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវពង្រឹងនិងបង្កើនប្រសិទ្ធភាពភារកិច្ចសំខាន់ៗដូចតទៅ :

- ឯកអគ្គរាជទូត អគ្គកុងស៊ុល ភារៈធារី ដែលជាប្រធានបេសកកម្មការទូត ហើយមានតួនាទីជាប្រធានស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ជាអាណាប័កផ្ទេរសិទ្ធិពីរដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។ នៅដើមត្រីមាសនីមួយៗ គ្រប់ស្ថានតំណាងនៅបរទេស ត្រូវបានផ្តល់តាមរយៈអាណត្តិបើកប្រាក់លើថវិកា របស់ក្រសួង ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ នូវទាយជទានរួមមួយស្មើនឹង មួយភាគបួន នៃឥណទានប្រចាំឆ្នាំ ។
- ប្រធានស្ថានតំណាងនៅបរទេស ត្រូវចាត់នីតិវិធីចំណាយ ក្រោមការទទួលខុសត្រូវរបស់ខ្លួន ធ្វើការសន្យានិងជំរះបញ្ជីចំណាយ នៃស្ថានតំណាងរបស់ខ្លួន នៅក្នុងកំរិតនៃឥណទានដែលបានបែងចែកជូន និង មូលនិធិដែលបានទទួល ។
- នៅរាល់ស្ថានតំណាងកម្ពុជានីមួយៗ នៅបរទេស ភ្នាក់ងារគណនេយ្យ ដែលមានតួនាទីជាគណនេយ្យករ

ដោយឡែក ត្រូវបូកសរុបនូវរបាយការណ៍ចំណូល-ចំណាយដែលកើតមានឡើងក្នុងខែ ហើយផ្ញើមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិមួយច្បាប់ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ( អង្គភាពគ្រប់គ្រងរូបិយប័ណ្ណ ហ្វាក់ លេខ ៨៥៥ ២៣ ៤២៨ ២០០ ) មួយច្បាប់ឱ្យបានមុនថ្ងៃទី ០៥ នៃខែនីមួយៗ ។ ផ្អែកលើមូលដ្ឋាន ចំណូលដែលទទួលបាន ពីភ្នាក់ងារ គណនេយ្យតាមស្ថានតំណាងនិមួយៗ អង្គភាពគ្រប់គ្រងរូបិយប័ណ្ណត្រូវកត់ត្រាបដិភាគនៃចំណូលនេះ លើទាយជ្ជទានដែល ត្រូវផ្តល់ជូនសាមីស្ថានតំណាង ដោយជូនដំណឹងជាលាយល័ក្ខអក្សរអំពីចំនួនកត់ត្រានេះ ។ នៅពេលទទួលបានសេចក្តីជូន ដំណឹងពីអង្គភាពគ្រប់គ្រងរូបិយប័ណ្ណ ភ្នាក់ងារគណនេយ្យត្រូវចុះលេខនា ដូចគ្នានឹងលេខនាដែលបានពណ៌នានេះ ។

- តាមរយៈតួនាទីជាគណនេយ្យករដោយឡែករបស់ស្ថានតំណាងនៅបរទេស ភ្នាក់ងារគណនេយ្យនីមួយៗ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ( អគ្គាធិការដ្ឋាន ) និង ត្រូវបានវិនិច្ឆ័យផងដែរពីអាជ្ញាធរសវនកម្មជាតិ ។

- ចាប់ពីត្រីមាសទីមួយ ឆ្នាំ ២០០៤ តទៅ តាមរយៈអាណត្តិបើកប្រាក់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹង ធ្វើការបង្វែរចំនួនទឹកប្រាក់ដែលត្រូវផ្តល់ ចូលគណនីចរន្ត របស់ស្ថានតំណាងទាំងនោះ ដែលបានបើកនៅធនាគារណាមួយនៅកន្លែងខ្លួន ដោយផ្អែកតាមរបាយការណ៍ចំណូលដែលកើតមានឡើងក្នុងខែរបស់គ្រប់ស្ថានតំណាងដែលបានផ្ញើមកក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ដូចនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹង ធ្វើការបង្វែរសាច់ប្រាក់ជូនភ្លាមត្រឹមតែចំនួនទឹកប្រាក់ដែលនៅសល់ក្រោយពីបានដកចេញនូវចំនួនចំណូលជាក់ស្តែងដែលបានរាយការណ៍មកនោះ មានន័យថា អំណើះតទៅ ការបង់ចំណូលសាច់ប្រាក់របស់ស្ថានតំណាងនិមួយៗ នៃព្រះរាជាណាចក្រកម្ពុជានៅបរទេសលែងត្រូវបានបញ្ជូនសាច់ប្រាក់មកធ្វើការបង់ជាក់ស្តែងនៅរតនាគារជាតិក្នុងស្រុក ដូចមុនៗទៀតហើយ ។

ទទួលបានសារាចរនេះ សូមព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត-ក្រុង និងប្រធានមន្ទីរជំនាញគ្រប់ខេត្ត-ក្រុង ត្រូវយកចិត្តទុកដាក់សហការគ្នា អនុវត្តឱ្យបានហ្មត់ចត់និងមានប្រសិទ្ធភាពខ្ពស់បំផុត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

<u>ចម្លងជូន</u> :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់ខេត្ត-ក្រុង
- គ្រប់មន្ទីរជំនាញខេត្ត-ក្រុង
- ឯកសារនិងកាលប្បវត្តិ